# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត

ផ្នែកអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិ

## សម្រាប់មុខវិជ្ជា

## ១.ការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ





## ២.ការកែច្នៃផលិតផលវារីសត្វ




នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ឆ្នាំ២០២៣

# បុព្វកថា

វិស័យអប់រំ គឺជាវិស័យអាទិភាពមួយក្នុងការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គមជាតិ និងសេដ្ឋកិច្ច ជាពិសេសការអភិវឌ្ឍធនធានមនុស្សឱ្យក្លាយជាមូលធនមនុស្សដែលមានជំនាញបច្ចេកទេសច្បាស់លាស់ សមត្ថភាពពិតប្រាកដ និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបំពេញគ្រប់លក្ខខណ្ឌការងារតាមតម្រូវការរបស់សង្គមជាតិ។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកម្មវិធីផ្តល់សេវាអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងអភិវឌ្ឍកម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេស សម្រាប់អនុវត្តនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ដើម្បីតម្រង់ទិសសិស្សដែលបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ឱ្យទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេសសមស្របតាមឧបនិស្ស័យ តម្រូវការទីផ្សារពលកម្ម មានសមត្ថភាពបំពេញការងារ បង្កើតការងារ បន្តការសិក្សាពេញមួយជីវិត និងចូលរួមអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដើម្បីឱ្យកម្ពុជាក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងឆ្នាំ ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

កម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតផ្នែកអប់រំបច្ចេកទេស ត្រូវបានរៀបចំឡើងដោយកំណត់ច្បាស់ពីគោលបំណង សមត្ថភាពអនុវត្ត សមត្ថភាពដោះស្រាយបញ្ហា ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងាររបស់សហគមន៍ និងស្ថានភាពការងាររបស់ប្រទេសកម្ពុជា។ កម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតនេះជាត្រីវិស័យជួយដល់លោកគ្រូ អ្នកគ្រូ នាយកសាលា សហគមន៍ និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងការបណ្តុះបណ្តាលសិស្សានុសិស្សឱ្យមានសមត្ថភាពវិជ្ជាជីវៈមួយច្បាស់លាស់ផ្នែកវារីសត្វ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដោយស្មោះ ចំពោះទីភ្នាក់ងារអភិវឌ្ឍន៍សាធារណរដ្ឋឆែក បុគ្គលិកអប់រំ វិស័យឯកជន អ្នកឯកទេសមកពីគ្រឹះស្ថានឧត្តមសិក្សាផ្នែកវារីវប្បកម្មទាំងអស់ ដែលបានចូលរួមចំណែកបំពេញការងារនេះយ៉ាងសកម្មរហូតបានលទ្ធផលជាផ្លែផ្កា និងសូមកោតសរសើរចំពោះក្រុមការងារនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈនិងគណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត ដែលខិតខំយកអស់កម្លាំងកាយ ចិត្ត ប្រាជ្ញា និងស្មារតីកសាងកម្មវិធីសិក្សាបន្ថែមផ្នែកវារីសត្វនេះ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំចំពោះការយកចិត្តទុកដាក់របស់បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ វិស័យឯកជន និងសហគមន៍ ក្នុងការចូលរួមអនុវត្តកម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេសឱ្យសម្រេចបានជោគជ័យ ដើម្បីបណ្តុះបណ្តាលធនធានមនុស្សឱ្យមានសមត្ថភាពភាពពេញលេញ ទទួលបានការងារសមរម្យ និងជាពលរដ្ឋប្រកបដោយគុណភាព និងផលិតភាពខ្ពស់។

ថ្ងៃ ព្រហស្បតិ៍ ៧រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

ការរៀបចំកម្មវិធីសិក្សា គឺជាលំនាំនៃការធ្វើសេចក្តីសម្រេចចិត្តក្នុងការកំណត់គោលដៅ ការជ្រើសរើសខ្លឹមសារ ការកសាងរចនាសម្ព័ន្ធ និងលំដាប់លំដោយនៃមុខវិជ្ជា និងមេរៀននីមួយៗ។ គោលបំណងនៃការរៀបចំកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតបន្ថែមលើជំនាញបសុវប្បកម្ម និងជំនាញកែច្នៃអាហារ ដោយផ្តោតលើមុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ និងមុខវិជ្ជាការកែច្នៃផលិតផលវារីសត្វ គឺដើម្បីចូលរួមអភិវឌ្ឍជំនាញបច្ចេកទេសនិងវិជ្ជាជីវៈផ្នែកចិញ្ចឹមវារីសត្វដល់សិស្សានុសិស្ស ដោយផ្សារភ្ជាប់បច្ចេកទេសក្នុងការបង្កាត់ពូជ ការចិញ្ចឹមបង្កើនទិន្នផល សំដៅដល់ការកែច្នៃទិន្នផលជាផលិតផលសម្រេច ឆ្លើយតបទៅនឹងតម្រូវការសហគមន៍ ទីផ្សារការងារក្នុងតំបន់ និងបន្តការសិក្សាពេញមួយជីវិត និងចូលរួមលើកកម្ពស់វិស័យវារីវប្បកម្មនៅកម្ពុជា។

កម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត មុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ និងមុខវិជ្ជាការកែច្នៃផលិតផលវារីសត្វ ត្រូវបានរៀបចំជាបីកម្រិតថ្នាក់គឺ ឆ្នាំទី១ ទី២ និងទី៣ ដោយបានកំណត់នូវសមត្ថភាពរំពឹងទុកក្រោយបញ្ចប់កម្មវិធីសិក្សា និងវត្ថុបំណងច្បាស់លាស់តាមមេរៀននីមួយៗលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា របាយម៉ោងសិក្សា សម្ភារឧបទ្ទេស ដែលស្របជាមួយនឹងក្របខណ្ឌកម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេស។ ក្នុងនោះដែរ សម្រាប់មុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ **ឆ្នាំទី១** ត្រូវបានរៀបចំឡើងចំនួន០៥មេរៀន **ឆ្នាំទី២** ចំនួន៤មេរៀន និង**ឆ្នាំទី៣** ចំនួន៤មេរៀន ដោយឡែកមុខវិជ្ជាការកែច្នៃផលិតផលវារីសត្វ **ឆ្នាំទី១** ត្រូវបានរៀបចំឡើងចំនួន០៣មេរៀន **ឆ្នាំទី២** ចំនួន២មេរៀន និង**ឆ្នាំទី៣** ចំនួន២មេរៀន។

គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា ជឿជាក់យ៉ាងមុតមាំថា សៀវភៅកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតនេះពិតជាមានប្រយោជន៍ដល់ការសិក្សារបស់សិស្ស ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ផ្នែកអប់រំបច្ចេកទេសឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាព។ ប្រសិនបើមានការខុសឆ្គងត្រង់ប្រការណាមួយ សូមអធ្យាស្រ័យ និងអភ័យទោស ហើយសូមជួយរិះគន់ក្នុងន័យស្ថាបនាដើម្បីជាគំនិតក្នុងការកែលម្អនៅពេលក្រោយបន្តទៀត។

ជាចុងក្រោយសូមថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ អ្នកសិក្សា និងគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ដែលបានផ្តល់ជាឯកសារជំនួយ ក៏ដូចជាព័ត៌មានជាច្រើនដែលមានប្រយោជន៍ដើម្បីរៀបរៀងចងក្រង សៀវភៅកម្មវិធីសិក្សានេះឱ្យមានលក្ខណៈពេញលេញ និងសម្បូរបែប សម្រាប់គាំទ្រលើដំណើរការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាពខ្ពស់។

**គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត**

## មាតិកា


ជំពូកទី១ ........................................................................................................1

១.១-សេចក្តីផ្តើម ........................................................................................................1

១.២- គោលបំណង ........................................................................................................2

១.៣- សមត្ថភាពរំពឹងទុកក្រោយបញ្ចប់ការសិក្សា........................................................................2

១.៤- ការអនុវត្តកម្មវិធីសិក្សា ........................................................................................3

១.៤.១- សេចក្តីណែនាំមូលដ្ឋាន ........................................................................................3

១.៤.២- សេចក្តីណែនាំការអនុវត្តការបង្រៀន និងរៀន ........................................................................3

១.៥- តារាងកម្មវិធីសិក្សា ........................................................................................4

១.៦- របាយម៉ោងសិក្សាតាមជំនាញ និងមុខវិជ្ជា ........................................................................5

ជំពូកទី២ ........................................................................................................6

២.១- មុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ១ ........................................................6

២.១.១- សម្រាប់ឆ្នាំទី១ ........................................................................................................6

២.២- មុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ២ ........................................................14

២.២.១- សម្រាប់ឆ្នាំទី២ ........................................................................................................14

២.៣- មុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ៣ ........................................................21

២.៣.១- សម្រាប់ឆ្នាំទី៣........................................................................................................21

ជំពូកទី៣........................................................................................................29

៣.១- មុខវិជ្ជាការកែច្នៃផលិតផលវារីសត្វ១........................................................................29

៣.១.១-សម្រាប់ឆ្នាំទី១ ........................................................................................................29

៣.២- មុខវិជ្ជាការកែច្នៃផលិតផលវារីសត្វ២ ........................................................................33

៣.២.១- សម្រាប់ឆ្នាំទី២........................................................................................................33

៣.៣- មុខវិជ្ជាការកែច្នៃផលិតផលវារីសត្វ៣........................................................................37

៣.៣.១- សម្រាប់ឆ្នាំទី៣.....37
**សន្ធានុក្រម**.....41
**គណៈកម្មការ**.....42
**ឯកសារយោង**.....43

# ជំពូកទី១
# ទិដ្ឋភាពរួមនៃកម្មវិធីសិក្សា

## ១.១-សេចក្ដីផ្ដើម

ការអភិវឌ្ឍកម្មវិធីសិក្សា សំដៅដល់ការធានានូវសមត្ថភាពរបស់សិស្សក្រោយពីបញ្ចប់ការសិក្សាឱ្យទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា សម្រាប់ប្រកបកិច្ចការរស់នៅប្រចាំថ្ងៃ និងសម្រាប់បន្តការសិក្សាពេញមួយជីវិត។ ជាងនេះទៅទៀត កម្មវិធីសិក្សាគឺធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំដែលឆ្លើយតបទៅនឹងការប្រែប្រួលរបស់ពិភពលោក និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារទាំងក្នុងស្រុក និងសកលលោក។ ស្របជាមួយគ្នានេះដែរ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលមានមហិច្ឆតាក្នុងការផ្លាស់ប្ដូរកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ បានចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាកត្តាគន្លឹះក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងសម្រាប់ការប្រកួតប្រជែងក្នុងប្រទេសតំបន់ និងពិភពលោកនាពេលអនាគត។

ការអភិវឌ្ឍជំនាញសម្រាប់យុវជន គឺជាចំណុចអាទិភាពមួយដែលក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងជំរុញដល់យុវជននូវជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម បង្កើនឱកាសទទួលបានការងារ និងសំដៅប្រែក្លាយយុវជនឱ្យទៅជាធនធានមនុស្សប្រកបដោយសមត្ថភាព និងគុណធម៌ សម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ ការអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ បានបង្កើតនូវសមត្ថភាពជំនាញដល់សិស្ស ដោយផ្ដោតការយកចិត្តទុកដាក់លើការជួយសិស្សឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាសម្រាប់មាគ៌ាអាជីពដែលពួកគេបានជ្រើសរើស និងអភិវឌ្ឍអត្តសញ្ញាណ បុគ្គលិកលក្ខណៈ និងទំនួលខុសត្រូវក្នុងនាមជាពលរដ្ឋពេញលេញ។

គោលដៅនៃការអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ គឺបណ្ដុះបណ្ដាលសិស្សដោយផ្ដោតទៅលើការអប់រំភាពម្ចាស់ការតស៊ូព្យាយាម ការអប់រំគំនិតច្នៃប្រឌិត ការរៀនពេញមួយជីវិត បំណិនដោះស្រាយបញ្ហា និងបំណិនទំនាក់ទំនង ដែលចំណេះដឹងទាំងនោះទាមទារឱ្យធ្វើបច្ចុប្បន្នកម្មទៅតាមចំណេះដឹងដែលបង្កើតថ្មីៗ និងការវិវត្តរបស់សង្គម។

ឆ្លើយតបជាមួយគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអភិវឌ្ឍមូលធនមនុស្ស តាមរយៈការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសវិជ្ជាជីវៈ ទីភ្នាក់ងារអភិវឌ្ឍសារជារណៈរដ្ឋឆែក ដែលជាដៃគូអភិវឌ្ឍក្នុងវិស័យអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅកម្ពុជា បានផ្ដល់ការគាំទ្រលើការបញ្ជ្រាបផ្នែកវារីវប្បកម្ម ក្នុងកម្មវិធីសិក្សាលើការបង្កាត់ភ្ញាស់ និងបច្ចេកទេសចិញ្ចឹមវារីសត្វ និងការកែច្នៃផលិតផលវារីសត្វ ដល់សិស្សានុសិស្សនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស។

## ១.២- គោលបំណង

កម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតលើ**មុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ និងមុខវិជ្ជាការកែច្នៃផលិតផលវារីសត្វ** រៀបចំឡើងក្នុងគោលបំណងអភិវឌ្ឍសមត្ថភាពបន្ថែមដល់សិស្ស**ជំនាញបសុវប្បកម្ម និងជំនាញកែច្នៃអាហារ** ក្នុងការចូលរួមអភិវឌ្ឍជំនាញបច្ចេកទេសនិងវិជ្ជាជីវៈផ្នែកចិញ្ចឹមវារីសត្វដល់សិស្ស ដោយផ្សារភ្ជាប់ការចិញ្ចឹមតាមលក្ខណៈបច្ចេកទេសដើម្បីបង្កើនទិន្នផលខ្ពស់ និងសំដៅដល់ការកែច្នៃទិន្នផលប្រកបដោយភាពច្នៃប្រឌិត និងស្របតាមស្តង់ដារគុណភាពអាហារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសហគមន៍ ទីផ្សារការងារក្នុងតំបន់ និងបន្តការសិក្សាពេញមួយជីវិត និងចូលរួមអភិវឌ្ឍវិស័យវារីវប្បកម្មឱ្យមាននិរន្តភាព។

## ១.៣- សមត្ថភាពរំពឹងទុកក្រោយបញ្ចប់ការសិក្សា

នៅពេលដែលសិស្សបញ្ចប់ឆ្នាំសិក្សាតាមរយៈកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតនេះសិស្សនឹងទទួលបានចំណេះដឹងប្រកបដោយគុណភាពខ្ពស់ តាមរយៈការសិក្សាទ្រឹស្តី ការអនុវត្តផ្ទាល់ ទស្សនកិច្ចសិក្សា ការចុះកម្មសិក្សានៅតាមកសិដ្ឋាន ការសិក្សាស្រាវជ្រាវពីស្ថានភាពជាក់ស្តែង និងការងារគម្រោងតាមរយៈការពិសោធ និងអង្កេត។ សមត្ថភាពបច្ចេកទេសជំនាញដែលសិស្សនឹងទទួលបានមានដូចខាងក្រោម៖

### ក- មុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ

- មានចំណេះដឹងមូលដ្ឋានលើច្បាប់ បទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធទៅនឹងវិស័យវារីវប្បកម្ម
- មានចំណេះដឹងក្នុងការប្រើប្រាស់វិធីសាស្ត្រទប់ស្កាត់ និងការការពារជំងឺលើប្រភេទវារីសត្វ
- បច្ចេកទេសជំនាញក្នុងការបង្កាត់ពូជផ្នែកវារីសត្វដូចជាត្រី និងកង្កែប
- បច្ចេកទេសជំនាញក្នុងចិញ្ចឹមវារីសត្វដូចជាត្រី កង្កែប កន្ធាយ បង្កងទទួលបានទិន្នផលខ្ពស់
- បច្ចេកទេសជំនាញក្នុងការប្រើប្រាស់សម្ភារឧបទ្ទេសក្នុងការបង្កាត់ពូជ និងចិញ្ចឹមវារីសត្វសមស្របតាមប្រភេទវារីសត្វ
- បណ្តុះគំនិតក្នុងការធ្វើវារីវប្បកម្មសមស្របទៅតាមស្ថានភាពជាក់ស្តែង និងអនុវត្តក្នុងការធ្វើវារីវប្បកម្មល្អ(GAqP) និងបណ្តុះគំនិតសហគ្រិនភាពលើអាជីពចិញ្ចឹមវារីសត្វសម្រាប់ជីវភាពរស់នៅប្រកបដោយគុណភាព និងគុណធម៌
- មានទំនុកចិត្តក្នុងការច្នៃប្រឌិត និងទំនួលខុសត្រូវខ្ពស់ក្នុងការងារ។

### ខ- មុខវិជ្ជាការកែច្នៃផលិតផលវារីសត្វ

- មានចំណេះដឹងកែច្នៃផលិតផលវារីសត្វលើការឆ្អើរ ផ្អាប់ ការបន្ទុំ(ទឹកត្រី) ការសម្ងួត ការកែច្នៃជាប្រភេទសាច់ក្រក សាច់ប៉ាតេ
- មានចំណេះដឹងលើផ្នែកច្បាប់ និងស្តង់ដារសុវត្ថិភាពចំណីអាហារ
- បច្ចេកទេសក្នុងការកែច្នៃប្រភេទវារីសត្វស្របតាមតម្រូវការទីផ្សារចំណីអាហារ
- បច្ចេកទេសក្នុងការប្រើប្រាស់សម្ភារក្នុងការកែច្នៃប្រភេទវារីសត្វបានត្រឹមត្រូវ

- បណ្តុះគំនិតកែច្នៃអាហារស្របតាមស្តង់ដារចំណីអាហារ និងប្រកបដោយគុណធម៌
- មានទំនុកចិត្តក្នុងការច្នៃប្រឌិត និងទំនួលខុសត្រូវខ្ពស់ក្នុងការងារ។

## ១.៤- ការអនុវត្តកម្មវិធីសិក្សា

### ១.៤.១- សេចក្តីណែនាំមូលដ្ឋាន

ក- សាលារៀនគោលដៅរបស់គម្រោងចាំបាច់ត្រូវអនុវត្តលើកម្មវិធីសិក្សាបន្ថែមនេះ ដោយដាក់បញ្ជ្រាបនៅក្នុងជំនាញបសុវប្បកម្ម និងអាចអនុវត្តទៅលើជំនាញផ្សេងៗទៀតតាមលទ្ធភាពជាក់ស្តែង ដែលសាលារៀនអាចអនុវត្តបាន

ខ- សាលារៀនអាចរៀបចំម៉ោងសិក្សា ដែលមានចែងក្នុងកម្មវិធីសិក្សានេះទៅតាមតម្រូវការជាក់ស្តែងដើម្បីសម្រេចបានតាមគោលបំណងនៃកម្មវិធីសិក្សា

គ- ពេលវេលា និងម៉ោងសិក្សាតាមបណ្តាមេរៀនសិក្សា គួរត្រូវបានរៀបចំដោយសាលារៀន និងឱ្យស្របតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានក្នុងរបាយម៉ោងសិក្សា។

### ១.៤.២- សេចក្តីណែនាំការអនុវត្តការបង្រៀន និងរៀន

ក- សាលារៀនអាចរៀបចំក្រុមសិក្សាតាមរបៀបផ្សេងៗគ្នា អាស្រ័យតាមស្ថានភាពជាក់ស្តែងនៃក្រុមសិក្សានោះដើម្បីអនុវត្តតាមកម្មវិធីសិក្សា

ខ- សាលារៀនអាចកំណត់យកបណ្តាមេរៀនចាំបាច់ សម្រាប់មុខវិជ្ជានីមួយៗប្រសិនបើមានការចាំបាច់

ឃ- សាលារៀនត្រូវរៀបចំ និងអនុវត្តកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតនេះដោយយកចិត្តទុកដាក់ចំពោះបញ្ហាដូចខាងក្រោម៖

- អនុវត្តកម្មវិធីសិក្សានេះតាមវិធីមួយដែលសមស្រប និងយកចិត្តទុកដាក់តាមលំដាប់លំដោយនៃមេរៀននីមួយៗ
- ផ្តល់ដល់សិស្សនូវកម្លាំងចិត្តក្នុងការសិក្សាឱ្យទទួលបានចំណេះដឹងអំពីបណ្តាវត្ថុបំណង ដែលមានរៀបរាប់ទៅតាមកម្រិតថ្នាក់(ឆ្នាំ)នីមួយៗ ដោយផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់ការរៀន និងអនុវត្តវិធីបង្រៀនសមស្របតាមសមត្ថភាពរបស់សិស្ស
- យកចិត្តទុកដាក់ក្នុងការធ្វើឱ្យមានការយល់ដឹងអំពីបញ្ញត្តិ និងគោលការណ៍មូលដ្ឋាន ហើយអនុវត្តក្នុងស្ថានភាពថ្មី របៀបនៃការសិក្សាតាមរយៈការសាកសួរជាជាងការសិក្សាដើម្បីចងចាំ។ ជាពិសេសត្រូវផ្តោតការយកចិត្តទុកដាក់លើសមត្ថភាពទាញយកព័ត៌មានតាមរយៈការប្រើប្រាស់សម្ភារសិក្សាផ្សេងៗ
- អនុញ្ញាតឱ្យសិស្សមានឱកាសដោះស្រាយបញ្ហា ដោយផ្តោតការយកចិត្តទុកដាក់លើសមត្ថភាពសិក្សារៀនបែបសហការក៏ដូចជាការបង្រៀនជាបុគ្គល ឬជាក្រុម

- លើកទឹកចិត្តការចូលរួមយ៉ាងសកម្មរបស់សិស្ស ក្នុងសកម្មភាពទាំងឡាយដូចជា ការពិសោធ ការអង្កេត ការប្រមូលទិន្នន័យ ហត្ថកម្ម ការពិភាក្សា ការធ្វើបទបង្ហាញ
- ក្នុងពេលអនុវត្តសកម្មភាពពិសោធន៍ ត្រូវយកចិត្តទុកដាក់ បម្រុងប្រយ័ត្ន ដើម្បីសុវត្ថិភាពក្នុងការប្រើប្រាស់គ្រឿងម៉ាស៊ីន និងសម្ភារពិសោធន៍
- ណែនាំសកម្មភាពបង្រៀន គួរជួយឱ្យសិស្សចាកចេញពីផ្នត់គំនិតរើសអើងតួនាទី និងយេនឌ័រ
- ប្រើប្រាស់ធនធានមនុស្ស និងធនធានរូបវន្តរបស់សហគមន៍ ដើម្បីធ្វើឱ្យការសិក្សាមុខជំនាញ និងសកម្មភាពក្រៅម៉ោងសិក្សាប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព
- សម្របសម្រួលកែលម្អសកម្មភាពបង្រៀនរបស់គ្រូ តាមរយៈការប្រជុំគ្រូដែលបង្រៀនតាមកម្រិតថ្នាក់(ឆ្នាំ) ដូចជាការប្រជុំក្រុមបច្ចេកទេសគ្រូបង្រៀនមុខវិជ្ជាដូចគ្នា ការស្រាវជ្រាវ ការងារអប់រំ និងកម្មវិធីបំប៉នសមត្ថភាពគ្រូ និងទស្សនកិច្ចសិក្សា
- វាស់ស្ទង់នូវកម្រិតនៃការរៀបចំកម្មវិធីសិក្សា និងកម្រិតនៃភាពសមស្រប និងប្រសិទ្ធភាពការអនុវត្តតាមឆ្នាំសិក្សានីមួយៗ និងប្រើប្រាស់លទ្ធផលនៃការវាស់ស្ទង់នោះក្នុងផែនការរៀបចំបំណែងចែកកម្មវិធីសិក្សា និងការអនុវត្តសម្រាប់ឆ្នាំសិក្សាបន្ទាប់។

## ១.៥- តារាងកម្មវិធីសិក្សា

| ជំនាញ | ឈ្មោះមុខវិជ្ជា | ឆ្នាំ/សប្តាហ៍ | | | ចំនួន |
|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | មេរៀន |
| បសុវប្បកម្ម | ការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ១ | ៣ | | | ៥ |
| | ការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ២ | | ៣ | | ៤ |
| | ការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ៣ | | | ៣ | ៤ |
| កែច្នៃអាហារ | ការកែច្នៃផលិតផលវារីសត្វ១ | ៣ | | | ៣ |
| | ការកែច្នៃផលិតផលវារីសត្វ២ | | ៣ | | ២ |
| | ការកែច្នៃផលិតផលវារីសត្វ៣ | | | ៣ | ២ |

## ១.៦- របាយម៉ោងសិក្សាតាមជំនាញ និងមុខវិជ្ជា

| ជំនាញ | មុខវិជ្ជា និងមេរៀន | កម្រិតឆ្នាំ | ម៉ោងសិក្សា | | |
|---|---|---|---|---|---|
| | | | សរុប | ទ្រឹស្តី | ប្រតិបត្តិ |
| បសុវប្បកម្ម | **ការបង្កាត់ពូជនិងបច្ចេកទេស ចិញ្ចឹមវារីសត្វ១**<br>មេរៀនទី១ សញ្ញាណនៃវារីវប្បកម្ម<br>មេរៀនទី២ ច្បាប់ជលផល<br>មេរៀនទី៣ លក្ខណៈជីវសាស្ត្រ និងសរីរវិទ្យាត្រី<br>មេរៀនទី៤ ប្រព័ន្ធ និងប្រភេទនៃការធ្វើវារីវប្បកម្ម<br>មេរៀនទី៥ វារីវប្បកម្មទឹកសាប | ១ | ១១៤ | ៥១ | ៦៣ |
| | **ការបង្កាត់ពូជនិងបច្ចេកទេស ចិញ្ចឹមវារីសត្វ២**<br>មេរៀនទី១ សំណង់វារីវប្បកម្ម<br>មេរៀនទី២ គុណភាពទឹក និងការគ្រប់គ្រងទឹក<br>មេរៀនទី៣ ការបង្កាត់ភ្ញាស់ និងការប្រើប្រាស់អ័រម៉ូន<br>មេរៀនទី៤ ផែនការផលិតកូនត្រីពូជ | ២ | ១១៤ | ៣២ | ៨២ |
| | **ការបង្កាត់ពូជនិងបច្ចេកទេស ចិញ្ចឹមវារីសត្វ៣**<br>មេរៀនទី១ ចំណី និងការផ្តល់ចំណី<br>មេរៀនទី២ ជំងឺ និងការការពារ<br>មេរៀនទី៣ ការគ្រប់គ្រង និងការប្រមូលផលត្រី<br>មេរៀនទី៤ ទីផ្សារ និងការដឹកជញ្ជូន | ៣ | ១១៤ | ៣៨ | ៧៦ |
| កែច្នៃអាហារ | **ការកែច្នៃផលិតផលវារីសត្វ១**<br>មេរៀនទី១ ច្បាប់ និងស្តង់ដារសុវត្ថិភាពចំណីអាហារ<br>មេរៀនទី២ ការឆ្អើរ<br>មេរៀនទី៣ ការផ្អាប់ | ១ | ១១៤ | ២៧ | ៨៧ |
| | **ការកែច្នៃផលិតផលវារីសត្វ២**<br>មេរៀនទី១ ការបន្ទំ( ទឹកត្រី )<br>មេរៀនទី២ ការសម្ងួត | ២ | ១១៤ | ២១ | ៩៣ |
| | **ការកែច្នៃផលិតផលវារីសត្វ៣**<br>មេរៀនទី១ ការកែច្នៃប្រហិត (ហតដក ប៉ាតេ)<br>មេរៀនទី២ ការកែច្នៃសាច់ក្រកត្រី | ៣ | ១១៤ | ១២ | ១០២ |

# ជំពូកទី២
# សេចក្តីបរិយាយកម្មវិធីសិក្សាលម្អិត
# មុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ

## ២.១- មុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ១

### ២.១.១- សម្រាប់ឆ្នាំទី១

| ព័ត៌មានអំពីមុខវិជ្ជា |
|---|
| • **ឈ្មោះមុខវិជ្ជា៖ ការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ១**<br>• **សេចក្តីផ្តើម៖** សម្រាប់ឆ្នាំទី១មុខវិជ្ជានេះសិក្សាអំពីច្បាប់ជលផល ប្រព័ន្ធ និងប្រភេទនៃការធ្វើវារីវប្បកម្ម សញ្ញាណនៃវារីវប្បកម្ម លក្ខណៈជីវសាស្ត្រ និងសរីរវិទ្យាត្រី និងវារីវប្បកម្មទឹកសាប។<br>• **វត្ថុបំណង៖**<br>**វិជ្ជាសម្បទា៖**<br>- រៀបរាប់បានត្រឹមត្រូវពីបញ្ញត្តិទូទៅនៃច្បាប់ជលផល<br>- ពិពណ៌នាបានត្រឹមត្រូវពីច្បាប់គតិយុត្តក្នុងការធ្វើវារីវប្បកម្ម<br>- រៀបរាប់បានពីប្រព័ន្ធ និងប្រភេទនៃការធ្វើវារីវប្បកម្ម<br>- រៀបរាប់បានពីចំណាត់ថ្នាក់សំខាន់ៗនៃប្រព័ន្ធវារីវប្បកម្ម និងប្រភេទវារិជាតិបានត្រឹមត្រូវ<br>- រៀបរាប់ពីលក្ខណៈជីវសាស្ត្រ និងសរីរៈវិទ្យារបស់សត្វត្រីបានត្រឹមត្រូវ<br>- ពិពណ៌នាបានត្រឹមត្រូវពីនិយមន័យវារីវប្បកម្មទឹកសាប។<br>**បំណិនសម្បទា៖**<br>- បកស្រាយបានច្បាស់លាស់ពីច្បាប់ជលផលដូចជាបទបញ្ញត្តិទូទៅ និងទោសបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនិងវិស័យជលផល<br>- កំណត់បានច្បាស់លាស់ពីប្រព័ន្ធនៃការធ្វើវារីវប្បកម្ម និងប្រភេទវារីវប្បកម្ម<br>- កំណត់ពីប្រភេទវារិជាតិបានត្រឹមត្រូវ<br>- អនុវត្តបានលើការធ្វើវារីវប្បកម្មល្អ (GAqP)<br>- កំណត់បានត្រឹមត្រូវពីលក្ខណៈជីវសាស្ត្រ និងសរីរវិទ្យារបស់សត្វត្រី<br>- អនុវត្តគោលការណ៍បច្ចេកទេសប្រភេទវារីវប្បកម្មទឹកសាបបានត្រឹមត្រូវ។<br>**ចរិយាសម្បទា៖**<br>- បណ្តុះស្មារតីការពារធនធានជលផល និងផ្សព្វផ្សាយពីច្បាប់ និងទោសបញ្ញត្តិនៃច្បាស់ជលផលដល់សហគមន៍<br>- បណ្តុះគំនិតក្នុងការធ្វើវារីវប្បកម្មសមស្របទៅតាមលទ្ធភាពជាក់ស្តែងក្នុងជីវភាពប្រចាំថ្ងៃ |

- បណ្តុះស្មារតីអនុវត្តការធ្វើវារីវប្បកម្មល្អ(GAqP)
- បណ្តុះគំនិតផ្សព្វផ្សាយពីបច្ចេកទេសនៃការចិញ្ចឹមត្រី និងកង្កែបដល់សហគមន៍
- បណ្តុះគំនិតសហគ្រិនភាពលើអាជីពចិញ្ចឹមវារីសត្វសម្រាប់ជីវភាពរស់នៅ
- បណ្តុះទម្លាប់អនុវត្តស៥ខ្ពស់ ក្នុងបន្ទប់ពិសោធន៍ និងបន្ទប់ប្រតិបត្តិ។

- **ឈ្មោះ មុខសញ្ញា និងចំនួនម៉ោង៖**
  - សិស្សថ្នាក់ឆ្នាំទី១ នៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
  - អនុវត្ត៖ ឆមាសទី១ និងទី២
  - ចំនួនមេរៀន៖ ០៥មេរៀន
  - ចំនួនម៉ោងសិក្សា៖ ១១៤ម៉ោង (ទ្រឹស្តី៥១ម៉ោង ប្រតិបត្តិ៦៣ម៉ោង)
- **វិធីសាស្ត្របង្រៀន៖ ការពន្យល់ ការអនុវត្តជាក់ស្តែង ការចុះទស្សនកិច្ចសិក្សា ការងារស្រាវជ្រាវ។**

## ព័ត៌មានអំពីមេរៀន

## មេរៀនទី១ សញ្ញាណនៃវារីវប្បកម្ម

**វត្ថុបំណង៖**

**វិជ្ជាសម្បទា**

- រៀបរាប់បានពីចំណាត់ថ្នាក់សំខាន់ៗនៃប្រព័ន្ធវារីវប្បកម្ម និងប្រភេទវារិជាតិ
- ពិពណ៌នាបានពីការអនុវត្តវារីវប្បកម្មល្អ។

**បំណិនសម្បទា**

- កំណត់ចំណាត់ថ្នាក់ប្រព័ន្ធវារីវប្បកម្មបានត្រឹមត្រូវ
- កំណត់ពីលក្ខណៈវារិជាតិបានត្រឹមត្រូវ
- បកស្រាយបានច្បាស់លាស់ពីការអនុវត្តវារីវប្បកម្មល្អ។

**ចរិយាសម្បទា**

- បណ្តុះស្មារតីឱ្យសិស្សអនុវត្តការធ្វើវារីវប្បកម្មល្អ (GAqP) និងផ្សព្វផ្សាយដល់សហគមន៍។

**សម្ភារឧបទ្ទេស៖**

- រូបភាពប្រភេទវារិជាតិ
- Computer LCD Projector, ក្រដាស Flip chat, ហ្វឺត ក្រដាស, បន្ទាត់។

| ខ្លឹមសារមេរៀន | ប្រតិបត្តិ | ម៉ោង | |
|---|---|---|---|
| | | ទ្រឹស្តី | ប្រតិបត្តិ |
| **មេរៀនទី១ សញ្ញាណនៃវារីវប្បកម្ម**<br>១.១- សេចក្តីផ្តើម<br>១.២- ចំណាត់ថ្នាក់ប្រព័ន្ធវារីវប្បកម្ម | - កិច្ចការស្រាវជ្រាវពីការធ្វើវារីវប្បកម្មល្អ សរសេររបាយការណ៍ និងធ្វើបទបង្ហាញ(ការងារក្រុម) | ៩ | ៣ |

| | | | |
|---|---|---|---|
| ១.២.១- វារីវប្បកម្មទឹកសាប<br>១.២.២- វារីវប្បកម្មទឹកភ្លាវ<br>១.២.៣- វារីវប្បកម្មទឹកប្រៃ<br>១.៣- វារិជាតិ<br>១.៣.១- វារិរុក្ខជាតិ<br>១.៣.១- វារីសត្វ<br>១.៤- ការអនុវត្តវារីវប្បកម្មល្អ (GAqP)<br>១.៤.១- និយមន័យ<br>១.៤.២- មូលដ្ឋាននៃការអនុវត្តវារីវប្បកម្មល្អ | - កិច្ចការស្រាវជ្រាវពីវារិជាតិលម្អ សរសេររបាយការណ៍ និងធ្វើបទបង្ហាញ(ការងារក្រុម) | | |

## មេរៀនទី២ ច្បាប់ជលផល

**វត្ថុបំណង៖**

**វិជ្ជាសម្បទា**

- រៀបរាប់បានត្រឹមត្រូវពីបញ្ញត្តិទូទៅនៃច្បាប់ជលផល
- ពិពណ៌នាបានត្រឹមត្រូវពីច្បាប់គតិយុត្តក្នុងការធ្វើវារីវប្បកម្ម
- ពិពណ៌នាបានពីមូលដ្ឋានក្នុងការគ្រប់គ្រងវារីវប្បកម្មតាមរយៈការចុះទស្សនកិច្ចសិក្សា។

**បំណិនសម្បទា**

- បកស្រាយបានច្បាស់លាស់ពីច្បាប់ជលផលដូចជាបទបញ្ញត្តិទូទៅ និងទោសបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនិងវិស័យជលផល
- ធ្វើបទបង្ហាញបានត្រឹមត្រូវពីសហគមន៍នេសាទ និងសហគមន៍វារីវប្បករ។

**ចរិយាសម្បទា**

- បណ្តុះស្មារតីការពារធនធានជលផល និងផ្សព្វផ្សាយពីឧបករណ៍ខុសច្បាប់ដល់សហគមន៍។

**សម្ភារឧបទ្ទេស៖**

- LCD Projector
- លិខិតបទដ្ឋាន គតិយុត្តពាក់ព័ន្ធជលផល
- ឯកសារច្បាប់ជលផល
- Website រដ្ឋបាលជលផល https://fia.maff.gov.kh/
- Website ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ https://web.maff.gov.kh/

| ខ្លឹមសារមេរៀន | ប្រតិបត្តិ | ម៉ោង | |
|---|---|---|---|
| | | ទ្រឹស្តី | ប្រតិបត្តិ |
| **មេរៀនទី២ ច្បាប់ជលផល**<br>២.១- បញ្ញត្តិទូទៅ<br>២.២- ការការពារ និងអភិរក្សជលផល<br>២.៣- ការធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាប និងទឹកសមុទ្រ<br>២.៤- ការគ្រប់គ្រងវារីវប្បកម្ម<br>២.៥- សមាគមន៍នេសាទ<br>២.៦- សមាគមន៍វារីវប្បករ<br>២.៧- អំពីលិខិតអនុញ្ញាត<br>២.៨- ទោសបញ្ញត្តិ | - ទស្សនកិច្ចកសិដ្ឋានចិញ្ចឹមវារីសត្វដែលនៅជិតៗក្នុងមូលដ្ឋានជលផលផ្នែកវារីវប្បកម្ម<br>- អញ្ជើញអ្នកជំនាញមកជួយពន្យល់ច្បាប់ជលផល<br>- ទៅមើលតំបន់អភិរក្សនៅជិតៗបើមាន<br>- ស្រាវជ្រាវអំពីសហគមន៍នេសាទ និងកិច្ចការស្រាវជ្រាវពីច្បាប់ជលផល | ៩ | ៣ |

## មេរៀនទី៣ លក្ខណៈជីវសាស្ត្រ និងសរីរវិទ្យាត្រី

**វត្ថុបំណង៖**

**វិជ្ជាសម្បទា**

- ពិពណ៌នាបានត្រឹមត្រូវពីរូបផ្គុំក្រៅ និងរូបផ្គុំក្នុងត្រី
- ពិពណ៌នាពីប្រព័ន្ធដំណកដង្ហើម របត់ឈាម រំលាយអាហារ និងប្រព័ន្ធបន្តពូជរបស់ត្រីបានត្រឹមត្រូវ
- ពិពណ៌នាបានត្រឹមត្រូវពីលក្ខណៈជីវសាស្ត្ររបស់សត្វត្រី។

**បំណិនសម្បទា**

- កំណត់បានច្បាស់លាស់ពីចរិតនៃការស៊ីចំណីរបស់ត្រី
- កំណត់ពីប្រព័ន្ធរំលាយអាហារ ដំណកដង្ហើម របត់ឈាម និងប្រព័ន្ធបន្តពូជត្រីបានច្បាស់លាស់តាមរយៈខ្លឹមសារមេរៀន និងវះកាត់ត្រីពិនិត្យសរីរាង្គខាងក្នុងត្រី
- កំណត់អត្តសញ្ញាណនៃលក្ខណៈជីវសាស្ត្រប្រភេទត្រី។

**ចរិយាសម្បទា**

- បណ្តុះទម្លាប់អនុវត្តការងារប្រកបដោយការទទួលខុសត្រូវ និងស្មារតីក្រុម
- បណ្តុះទម្លាប់អនុវត្តស៥ខ្ពស់ ក្នុងបន្ទប់ពិសោធន៍ និងបន្ទប់ប្រតិបត្តិ។

**សម្ភារឧបទ្ទេស៖**

- Computer LCD Projector
- រូបភាពត្រី រូបសំណាកកាយវិភាគវិទ្យាត្រី ត្រីស្រស់

- ឈុតវះកាត់
- ថាសចតុកោណកែង ស្រោមដៃពេទ្យ ម៉ាស់ ក្រដាសអនាម័យ ជ្រុញជ័រ
- អាវសក្នុងបន្ទប់ពិសោធន៍ ( White Gown )
- អាល់កុល ៩០% សាប៊ូលាងសម្អាត។

| ខ្លឹមសារមេរៀន | ប្រតិបត្តិ | ម៉ោង | |
|---|---|---|---|
| | | ទ្រឹស្តី | ប្រតិបត្តិ |
| **មេរៀនទី៣ លក្ខណៈជីវសាស្ត្រនិងសរីរវិទ្យាត្រី**<br>៣.១- លក្ខណៈជីវសាស្ត្រ<br>៣.១.១- ចរិតនៃការស៊ីចំណី<br>៣.១.២- ស្រទាប់នៃការស៊ីចំណី<br>៣.២- សរីរវិទ្យាត្រី<br>៣.២.១- រូបផ្ដុំត្រី<br>ក- រូបផ្ដុំខាងក្រៅ<br>ខ- រូបផ្ដុំខាងក្នុង<br>៣.២.២- ប្រព័ន្ធដំណកដង្ហើម<br>៣.២.៣- ប្រព័ន្ធរបត់ឈាម<br>៣.២.៤- ប្រព័ន្ធរំលាយអាហារ<br>៣.២.៥- ប្រព័ន្ធបន្តពូជ | - ពិនិត្យរូបផ្ដុំក្រៅត្រី<br>- វះកាត់ត្រីពិនិត្យសរីរាង្គក្នុងត្រី<br>- វះកាត់ត្រីពិនិត្យប្រព័ន្ធរំលាយអាហារ របត់ឈាម និងដំណកដង្ហើម | ១២ | ២១ |

## មេរៀនទី៤ ប្រព័ន្ធ និងប្រភេទនៃការធ្វើវារីវប្បកម្ម

### វត្ថុបំណង៖

**វិជ្ជាសម្បទា**

- រៀបរាប់បានពីប្រព័ន្ធការធ្វើវារីវប្បកម្មបានត្រឹមត្រូវ
- រៀបរាប់បានត្រឹមត្រូវពីប្រភេទនៃការធ្វើវារីវប្បកម្ម
- ពិពណ៌នាបានត្រឹមត្រូវពីប្រព័ន្ធកសិកម្មចម្រុះ។

**បំណិនសម្បទា**

- វិភាគបានពីប្រភេទនៃការចិញ្ចឹមទោល និងការចិញ្ចឹមចម្រុះលើផ្នែកវារីវប្បកម្ម
- កំណត់បានច្បាស់លាស់ពីការធ្វើប្រព័ន្ធកសិកម្មចម្រុះ
- កំណត់បានពីវិធីធ្វើវារីវប្បកម្មសមស្របទៅតាមលទ្ធភាពជាក់ស្ដែងក្នុងសហគមន៍
- ធ្វើបទបង្ហាញបានត្រឹមត្រូវពីប្រព័ន្ធ និងប្រភេទនៃការធ្វើវារីវប្បកម្ម។

**ចរិយាសម្បទា**

- បណ្ដុះស្មារតីឱ្យងាកមកចិញ្ចឹមត្រី កាត់បន្ថយការចាប់ត្រីពីធម្មជាតិ
- បណ្ដុះគំនិតក្នុងការធ្វើវារីវប្បកម្មសមស្របទៅតាមលទ្ធភាពជាក់ស្ដែងក្នុងជីវភាពប្រចាំថ្ងៃ។

**សម្ភារឧបទ្ទេស៖**

- Computer
- LCD Projector
- រូបភាពបង្ហាញពីប្រព័ន្ធ និងប្រភេទនៃការចិញ្ចឹមវារីសត្វ
- ក្រដាសផ្ទាំងធំ(ក្រដាសFlip Chat) ហ្វឺតសរសេរ។

| ខ្លឹមសារមេរៀន | ប្រតិបត្តិ | ម៉ោង | |
|---|---|---|---|
| | | ទ្រឹស្ដី | ប្រតិបត្តិ |
| **មេរៀនទី៤ ប្រព័ន្ធ និងប្រភេទនៃការធ្វើវារីវប្បកម្ម**<br>៤.១- ប្រវត្តិនៃការធ្វើវារីវប្បកម្ម<br>៤.២- ប្រព័ន្ធនៃការធ្វើវារីវប្បកម្ម<br>៤.២.១- វិបុលវប្បកម្ម (Extensive)<br>៤.២.២- ពាក់កណ្ដាលប្រពលវប្បកម្ម (Semi-Intensive)<br>៤.២.៣- ប្រពលវប្បកម្ម(Intensive)<br>៤.២.៤- វារីវប្បកម្មបែបទំនើប (Super-Intensive)<br>៤.៣- ប្រភេទនៃការធ្វើវារីវប្បកម្ម<br>៤.៣.១- ការចិញ្ចឹមទោល (Monoculture)<br>៤.៣.២-ការចិញ្ចឹមរួមផ្សំ (Polyculture)<br>៤.៤- ប្រព័ន្ធកសិកម្មចម្រុះ/IFM (ចម្រុះ) | - ទស្សនកិច្ចកសិដ្ឋានវារីសត្វដែលមាននៅជិតៗ និងសរសេររបាយការណ៍(ការងារក្រុម)<br>- កិច្ចការស្រាវជ្រាវពីប្រព័ន្ធ និងប្រភេទ នៃការធ្វើវារីវប្បកម្ម និងធ្វើបទបង្ហាញ(ការងារក្រុម) | ៦ | ៦ |

**មេរៀនទី៥ វារីវប្បកម្មទឹកសាប**

**វត្ថុបំណង៖**

**វិជ្ជាសម្បទា**

- រៀបរាប់បានត្រឹមត្រូវពីរបៀបនៃការជ្រើសរើសពូជ និងសម្ភារបង្កាត់ភ្ញាស់
- ពណ៌នាពីវិធីព្រលែងកូនត្រី និងកង្កែបបានត្រឹមត្រូវ
- ពណ៌នាពីរបៀបចិញ្ចឹម ថែទាំ និងការ តាមដានការលូតលាស់របស់ត្រី និងកង្កែប។

**បំណិនសម្បទា**

- កំណត់ពីវិធីសាស្ត្រជ្រើសរើសមេពូជបានត្រឹមត្រូវ
- កំណត់ពីវិធីសាស្ត្របង្កាត់ ភ្ញាស់កង្កែបបានច្បាស់លាស់
- ប្រើប្រាស់ចំណីបានត្រឹមត្រូវសមស្របតាមប្រភេទ និងអាយុសត្វត្រី
- ប្រើប្រាស់វិធីសាស្ត្រព្រលែងកូនត្រីប្រកបដោយសុវត្ថិភាព
- គណនាមេគុណចំណី(អត្រាប្តូរចំណីទៅជាសាច់) បានត្រឹមត្រូវ
- កំណត់អាត្រាទម្លាក់ពង ផ្សំកំណើត អត្រាញាស់ និងគង់វង្សរបស់សត្វត្រីបានច្បាស់លាស់។

**ចរិយាសម្បទា**

- បណ្តុះគំនិតសហគ្រិនភាពលើអាជីពចិញ្ចឹមវារីសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ
- បណ្តុះគំនិតឱ្យសិស្សផ្សព្វផ្សាយពីបច្ចេកទេសនៃការចិញ្ចឹមត្រី និងកង្កែបដល់សហគមន៍។

**សម្ភារឧបទ្ទេស៖**

- សៀវភៅកត់ត្រា ជញ្ជីង
- កំបោរស
- ចំណីត្រី ចំណីកង្កែប
- មេបាពូជកង្កែប មេបាពូជត្រីអណ្តែង
- Cinafact
- Moltilium/HGG/ Saline water Distil water
- សឺរាំង ម្ជុល( 1CC, 3CC, 5CC )
- ត្បាល់កិនថ្នាំ
- ជញ្ជីងអេឡិចត្រូនិច ,ជញ្ជីងប៉ុង
- ក្រណាត់ ចានដែក កែវភ្ញាស់ កន្ត្រង
- ជីអ៊ុយរ៉េ អំបិល កន្ទក់ម៉ដ្ឋ
- ប៉ូតាស្យូមពែម៉ងកាណាត
- ជីលាមកសត្វ ជីកំប៉ុស្ត ជីគីមី។

| ខ្លឹមសារមេរៀន | ប្រតិបត្តិ | ម៉ោង | |
|---|---|---|---|
| | | ទ្រឹស្តី | ប្រតិបត្តិ |
| **មេរៀនទី៥ វារីវប្បកម្មទឹកសាប**<br>៥.១- ការជ្រើសរើសទីតាំង<br>៥.២- ការជ្រើសរើសពូជចិញ្ចឹម<br>៥.៣- ប្រភេទស្រះសម្រាប់ចិញ្ចឹមត្រី | - រៀបចំស្រះ/ អាងចិញ្ចឹមកង្កែប/ ត្រី<br>- ផ្តល់ចំណីដល់ត្រី និងកង្កែប<br>- ថែទាំ និងតាមដានអត្រាធំធាត់ | ១៥ | ៣០ |

| | | | |
|---|---|---|---|
| ៥.៣.១- ការរៀបចំស្រះ<br>៥.៣.២- ការរៀបចំសម្ភារចិញ្ចឹម<br>៥.៣.៣- ដង់ស៊ីតេ និងការលែងកូនត្រី<br>៥.៤- វិធីសាស្ត្រលែងកូនពូជ និងដង់ស៊ីតេចិញ្ចឹម<br>៥.៤.១-ការបង្កាត់ភ្ញាស់ និង ចិញ្ចឹមកង្កែប<br>៥.៤.២-ការបង្កាត់ភ្ញាស់ និងត្រីអណ្តែង<br>៥.៥- ការថែទាំងនិងការផ្តល់ចំណី<br>៥.៦- ការត្រួតពិនិត្យអត្រាលូតលាស់<br>៥.៦.១- ប្រវែងកើនឡើង<br>៥.៦.២- ទម្ងន់កើនឡើង<br>៥.៦.៣- ទម្ងន់កើនឡើងប្រចាំថ្ងៃ<br>៥.៦.៤- មេគុណចំណី(អត្រាប្តូរចំណីទៅ ជាសាច់)<br>៥.៦.៥- អត្រាគង់វង្ស<br>៥.៧- ការត្រួតពិនិត្យគុណភាពទឹក និង គ្រប់គ្រងស្រះ<br>៥.៨- ការប្រមូលផល<br>៥.៨.១- ការប្រមូលផលបែបរំលោះ<br>៥.៨.២- ការប្រមូលផលទាំងអស់<br>៥.៩- ការធ្វើបញ្ជីចំណូល និងចំណាយ<br>៥.៩.១-បញ្ជីចំណាយ<br>៥.៩.២-បញ្ជីចំណូល | - អនុវត្តលើការចិញ្ចឹម និងបង្កាត់ ភ្ញាស់កង្កែប<br>- អនុវត្តប្រមូលផលកង្កែប និង ត្រីអណ្តែង<br>- អនុវត្តចិញ្ចឹមត្រីអណ្តែង | | |

## ២.២- មុខវិជ្ជាការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ២

### ២.២.១- សម្រាប់ឆ្នាំទី២

| ព័ត៌មានអំពីមុខវិជ្ជា |
|---|
| • **ឈ្មោះមុខវិជ្ជា៖ ការបង្កាត់ពូជ និងបច្ចេកទេសចិញ្ចឹមវារីសត្វ២**<br>• **សេចក្ដីផ្ដើម៖** មុខវិជ្ជានេះសិស្សនឹងសិក្សាអំពីសំណង់វារីវប្បកម្ម គុណភាពទឹក និងការគ្រប់គ្រងគុណភាពទឹក ការបង្កាត់ភ្ញាស់ និងការប្រើប្រាស់អ័រម៉ូន និងផែនការផលិតកូនត្រីពូជ។<br>**វត្ថុបំណង៖**<br>**វិជ្ជាសម្បទា៖**<br>- រៀបរាប់ពីប្រភេទសំណង់វារីវប្បកម្មបានត្រឹមត្រូវ<br>- ពិពណ៌នាបានត្រឹមត្រូវពីនិយមន័យគុណភាពទឹក និងសារៈសំខាន់របស់ក្នុងការធ្វើវារីវប្បកម្ម<br>- រៀបរាប់បានត្រឹមត្រូវពីគុណសម្បត្តិ និងគុណវិបត្តិរបស់ទឹក<br>- ពិពណ៌នាពីលំដាប់លំដោយនៃវិធីសាស្ត្របង្កាត់ភ្ញាស់បានត្រឹមត្រូវ<br>- រៀបរាប់ពីវិធីជ្រើសរើសមេពូជបានត្រឹមត្រូវ<br>- ពណ៌នាពីការធ្វើផែនការបង្កាត់ភ្ញាស់ពូជត្រីបានត្រឹមត្រូវ<br>- ពណ៌នាបានពីអត្រាលូតលាស់ និងអត្រាគង់បានត្រឹមត្រូវ។<br>**បំណិនសម្បទា៖**<br>- កំណត់ពីប្រភេទដីសម្រាប់ជីកស្រះចិញ្ចឹមត្រីបានត្រឹមត្រូវ<br>- ប្រើប្រាស់ជី និងកំបោរសបានត្រឹមត្រូវទៅតាមបច្ចេកទេសចិញ្ចឹមត្រី<br>- កំណត់បានត្រឹមត្រូវពីប៉ារ៉ាម៉ែត្រទឹកដែលល្អសម្រាប់ការចិញ្ចឹមត្រី<br>- ប្រើប្រាស់អរម៉ូនបានត្រឹមត្រូវលើការបង្កាត់ភ្ញាស់ត្រី<br>- ជ្រើសរើសប្រភេទត្រីដែលសមស្របជាមួយមជ្ឈដ្ឋានសម្រាប់យកមកចិញ្ចឹម<br>- រៀបចំផែនការផលិតកូនត្រីពូជបានច្បាស់លាស់ដោយមានរបាយការណ៍ និងសៀវភៅកត់ត្រាទិន្នន័យ។<br>**ចរិយាសម្បទា៖**<br>- បណ្ដុះទម្លាប់ល្អក្នុងការចិញ្ចឹមត្រីដោយពិនិត្យទីតាំង និងសំណង់ស្រះដែលសមស្របក្នុងការចិញ្ចឹមដើម្បីទទួលបានទិន្នផលខ្ពស់<br>- បណ្ដុះស្មារតីផ្សព្វផ្សាយដល់សហគមន៍លើវិធីសាស្ត្រចិញ្ចឹមត្រីដែលទទួលបានទិន្នផលខ្ពស់<br>- បណ្ដុះទម្លាប់ធ្វើការងារក្រុមដោយមានការទទួលខុសត្រូវ |

- បណ្ដុះស្មារតីមានបម្រុងប្រយ័ត្នក្នុងការត្រួតពិនិត្យផែនការឡើងវិញក្នុងការចិញ្ចឹមត្រី។
- **ឈ្មោះ មុខសញ្ញា និងចំនួនម៉ោង៖**
  - សិស្សថ្នាក់ឆ្នាំទី២ នៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
  - អនុវត្ត៖ ឆមាសទី១ និងទី២
  - ចំនួនមេរៀន៖ ០៤មេរៀន
  - ចំនួនម៉ោងសិក្សា៖ ១១៤ម៉ោង (ទ្រឹស្តី ៣២ម៉ោង ប្រតិបត្តិ ៨២ម៉ោង)
- **វិធីសាស្រ្តបង្រៀន៖ ការពន្យល់ ការអនុវត្តជាក់ស្តែង។**

## ព័ត៌មានអំពីមេរៀន

## មេរៀនទី១ សំណង់វារីវប្បកម្ម

**វត្ថុបំណង៖**

**វិជ្ជាសម្បទា**

- រៀបរាប់បានត្រឹមត្រូវពីប្រភេទសំណង់ស្រះ និងសំណង់បែរ
- រៀបរាប់ពីប្រភេទដីនិងការជ្រើសរើសទីតាំងជីកស្រះបានត្រឹមត្រូវ
- ពិពណ៌នាអំពីឧបករណ៍ក្នុងការចិញ្ចឹមបានច្បាស់លាស់។

**បំណិនសម្បទា**

- បែងចែកប្រភេទដីសម្រាប់ជីកស្រះចិញ្ចឹមត្រីបានត្រឹមត្រូវតាមរយៈការចុះអនុវត្តជាក់ស្តែងនៅក្នុងកសិដ្ឋាន និងបទពិសោធន៍បន្ទាប់ពីចុះទស្សនកិច្ចសិក្សា
- ប្រើប្រាស់កម្រិតដី និងកំបោរសបានត្រឹមត្រូវទៅតាមបច្ចេកទេសក្នុងការចិញ្ចឹមត្រី
- រៀបចំស្រះចិញ្ចឹម សង់អាង តំឡើងតង់ និងបែរ តាមលក្ខណៈបច្ចេកទេស។

**ចរិយាសម្បទា**

- បណ្តុះទម្លាប់ល្អក្នុងការចិញ្ចឹមត្រីដោយពិនិត្យទីតាំង និងសំណង់ស្រះដែលសមស្របក្នុងការចិញ្ចឹមដើម្បីទទួលបានទិន្នផលខ្ពស់។

**សម្ភារឧបទ្ទេស៖**

- Computer LCD Projector ហ្វឺត ក្រដាសផ្ទាំងធំ
- តង់ប្លាស្ទិក សំណាញ់បៃ ឫស្សី ទុយោ PVC កែង សុង ខ្សែភ្លើង
- ចបកាប់ ប៉ែល ចបជីក ញញួរ ពូថៅ ម៉ែត្រខ្សែ កំបិត ឬខ្វែវ
- រូបភាពគម្រូសំណង់ស្រះ
- ម៉ូទ័រផលិតខ្យល់ (តប្រព័ន្ធខ្យល់មាន ទុយោ PE,តេ កែង ស៊ុង ទុយោសេរ៉ូម, ក្បាលខ្យាច់)
- កំបោរស ដី (ជីសរីរាង្គ ជីគីមី)។

| ខ្លឹមសារមេរៀន | ប្រតិបត្តិ | ម៉ោង | |
|---|---|---|---|
| | | ទ្រឹស្តី | ប្រតិបត្តិ |
| **មេរៀនទី១ សំណង់វារីវប្បកម្ម**<br>១.១- សេចក្តីផ្តើម<br>១.២- សំណង់ស្រះ<br>១.២.១- ស្រះដី<br>១.២.២- អាងស៊ីម៉ងត៍<br>១.២.៣- ស្រះប្លាស្ទិក<br>១.៣- សំណង់បែរ<br>១.៣.១- បែរចល័ត<br>១.៣.២- បែរអចល័ត<br>១.៤- ការជ្រើសរើសទីតាំងសាងសង់ស្រះ<br>១.៥- ប្រភេទដីសម្រាប់ជីកស្រះ<br>១.៦- រចនាសម្ព័ន្ធស្រះក្នុងកសិដ្ឋាន<br>១.៦.១- ប្រព័ន្ធបញ្ចេញបញ្ចូលទឹក<br>១.៦.២- ការរៀបចំស្លាកសម្គាល់<br>១.៧- ការរៀបចំស្រះ<br>១.៧.១- ស្រះដី<br>ក. ស្រះចាស់<br>ខ. ស្រះថ្មី<br>១.៧.២-ស្រះស៊ីម៉ងត៍<br>ក. ស្រះចាស់<br>ខ. ស្រះថ្មី<br>១.៧.៣- ដី និងសារៈសំខាន់របស់ដី<br>ក. ដីសរីរាង្គ<br>ខ. ដីគីមី<br>១.៧.៦- កំបោរស និងការប្រើប្រាស់<br>ក. ប្រភេទកំបោរស<br>ខ. កម្រិតនៃការប្រើប្រាស់កំបោរស | - សាងសង់ស្រះប្លាស្ទិក/ដី<br>- អនុវត្តពិនិត្យគុណភាពដី<br>- អនុវត្តរៀបចំបែរចិញ្ចឹមត្រី<br>- រៀបចំប្រព័ន្ធអគ្គិសនី និងប្រព័ន្ធខ្យល់<br>- រៀបចំប្រព័ន្ធបញ្ចេញបញ្ចូលទឹក | ៦ | ៦ |

## មេរៀនទី២ គុណភាពទឹក និងការគ្រប់គ្រងទឹក

**វត្ថុបំណង៖**

**វិជ្ជាសម្បទា**

- ឱ្យនិយមន័យគុណភាពទឹកបានត្រឹមត្រូវ
- រៀបរាប់បានពីសារៈសំខាន់របស់ទឹកក្នុងការធ្វើវារីវប្បកម្ម។

**បំណិនសម្បទា**

- ពន្យល់បានត្រឹមត្រូវពីគុណសម្បត្តិទឹក
- កំណត់បានត្រឹមត្រូវលើប៉ារ៉ាម៉ែត្រទឹកដែលល្អសម្រាប់ការចិញ្ចឹមត្រី
- បែងចែកបានច្បាស់លាស់រវាងទឹកដែលមានក្ខណៈសមស្រប និងមិនសមស្របក្នុងការចិញ្ចឹមត្រី
- កែប្រែ និងដោះស្រាយគុណភាពទឹកដោយសន្សំសំចៃ សម្រាប់ប្រើប្រាស់ទឹកឡើងវិញ។

**ចរិយាសម្បទា**

- បណ្តុះទម្លាប់ល្អក្នុងការប្រើប្រាស់ទឹកសមស្របដើម្បីចិញ្ចឹមត្រី
- ចូលរួមស្រឡាញ់បរិស្ថានតាមរយៈការប្រើប្រាស់ទឹកដោយសន្សំសំចៃ។

**សម្ភារឧបទ្ទេស៖**

- DO meter, pH meter, Salinometer, Spectrophotometer, Electro conductivity meter, Ammonia set ឬជំនួសដោយ Test kit ( DO, pH NO2- , NO3- Alkalinity )
- Excel table ( pH DO Tem CO2 )
- ស្រោមដៃពេទ្យ ម៉ាស់ ស្បែកជើងវែង កែវដាក់សំណាកទឹក ខ្សែគោ
- Sochi Disk

<table>
<tr><th rowspan="2">ខ្លឹមសារមេរៀន</th><th rowspan="2">ប្រតិបត្តិ</th><th colspan="2">ម៉ោង</th></tr>
<tr><th>ទ្រឹស្តី</th><th>ប្រតិបត្តិ</th></tr>
<tr><td>មេរៀនទី២ គុណភាពទឹក និងការគ្រប់គ្រងទឹក<br>២.១- និយមន័យ<br>២.២- ប្រភព និងសារៈសំខាន់ទឹក<br>២.២.១- ប្រភពទឹក<br>២.២.២- សារៈសំខាន់ និងការប្រើប្រាស់ទឹក<br>២.៣- គុណសម្បត្តិទឹក<br>២.៣.១- លក្ខណៈរូបសាស្ត្រ<br>២.៣.២- លក្ខណៈគីមី</td><td>-អនុវត្តលើការត្រួតពិនិត្យ៖<br>-សីតុណ្ហភាព<br>-អុកស៊ីសែន<br>-ភាពជាអាស៊ីតបាស<br>-អាម៉ូញាក់<br>-អាល់កាឡាំង<br>-ការចម្លងអគ្គិសនីរបស់ទឹក<br>-ភាពថ្លា</td><td>១២</td><td>២៥</td></tr>
</table>

| | | | |
|---|---|---|---|
| ២.៣.៣- លក្ខណៈជីវសាស្ត្រនៃទឹក<br>២.៤- ការតាមដានគុណភាពទឹក | -ភាពល្អក់<br>-ការយកសំណាកទឹក | | |

